ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នប្រឆាំងអំពើពុករលួយ
**អង្គភាពប្រឆាំងអំពើពុករលួយ**
លេខ ០៣៩/សសរ/២៦ អ.ប.ព.

# សេចក្តីសម្រេច
# ស្តីពី
# ការទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត
# សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦
# នៅខេត្តស្ទឹងត្រែង

## ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- យោងសេចក្តីសម្រេចលេខ ០២៩/២៦ ស.រ អ.ប.ព. ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦ ស្តីពីការបង្កើតក្រុមការងារដឹកនាំការងារសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦
- យោងសេចក្តីជូនដំណឹងលេខ ០០៤/២៦ ស.ជ.ណ អ.ប.ព. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ ស្តីពីការជ្រើសរើសអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ដែលបានកំណត់អំពីចំនួនអ្នកសង្កេតការណ៍ស្ម័គ្រចិត្តរបស់ អ.ប.ព. នៅតាមរាជធានី-ខេត្តនីមួយៗ អំពីលក្ខខណ្ឌចុះឈ្មោះជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត (មានអាយុចាប់ពី ២១ ឆ្នាំឡើងទៅ - និស្សិត ឬបុគ្គលផ្សេងទៀតក្រៅពីព្រះសង្ឃ (កំពុងគង់ចាំព្រះវស្សា) គ្រូបង្រៀន មន្ត្រីរាជការសាធារណៈ និងអ្នកសារព័ត៌មាន - មិនត្រូវចូលរួមសង្កេតការណ៍ក្នុងមណ្ឌលប្រឡងដែលមានបងប្អូន សាច់ញាតិ ឬមិត្តភក្តិជាបេក្ខជនប្រឡងដែលនេះជាទំនាស់ផលប្រយោជន៍ - ត្រូវឬធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល/កិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការងារសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ - ត្រូវទាញយកកម្មវិធី Angkor Life មកប្រើប្រាស់សម្រាប់ការជូនដំណឹង និងTelegram សម្រាប់ទំនាក់ទំនងការងារសង្កេតការណ៍ - មានមធ្យោបាយ ធនធាន ពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញការងារសង្កេតការណ៍ស្ម័គ្រចិត្តដោយខ្លួនឯង រួមទាំងមធ្យោបាយធ្វើដំណើរ - គោរពតាមច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តជាធរមាន ការចាត់តាំង ដឹកនាំ ប្រគល់ភារកិច្ចរបស់ក្រុមដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល ជាពិសេសគោរពបានយ៉ាងខ្ជាប់ខ្ជួនបទប្បញ្ញត្តិ សេចក្តីណែនាំ យល់តួនាទីភារកិច្ចអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត និងអំពីលក្ខខណ្ឌសម្រេចជ្រើសរើសបេក្ខជន (អាទិភាពជ្រើសរើសបេក្ខជនដាក់ពាក្យមុន - និស្សិតកំពុងសិក្សាតាមគ្រឹះស្ថានសិក្សានានា - មិនធ្លាប់ចូលរួមសង្កេតការណ៍ - អាទិភាពនារី - មានអាយុច្រើន)
- យោងតម្រូវការចាំបាច់នៃការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ



អគារលេខ ៥៤ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Website: www.acu.gov.kh, E-mail: complaint@acu.gov.kh, info@acu.gov.kh
Tel: 023 223 954, 023 221 653, Hotline: 1282

## សម្រេច

ប្រការ ១._

**ខេត្តស្ទឹងត្រែង** មានអ្នកដាក់ពាក្យជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចំនួន ៨៧ នាក់ (អ្នកដាក់ពាក្យ)។ សម្រាប់ខេត្តស្ទឹងត្រែង អង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.) មានគម្រោងជ្រើសរើសអ្នកសង្កេតការណ៍ចំនួន ៣៨ នាក់ (ហៅថាអ្នកសង្កេតការណ៍)។

ក្នុងចំណោមអ្នកបានដាក់ពាក្យចំនួន ៣៨ នាក់ មុនគេបំផុត អ.ប.ព. បានពិនិត្យឃើញថា មានអ្នកដាក់ពាក្យចំនួន ១៦ ដែលមិនបានបំពេញគ្រប់តាមលក្ខខណ្ឌ ហេតុដូចនេះ អ.ប.ព. ក៏បានពិនិត្យពីលេខរៀង៣៩ ដល់ ៥៤ ក្នុងនោះក៏យើងបានពិនិត្យឃើញថា មិនទាន់គ្រប់លក្ខខណ្ឌ ដូច្នេះយើងបានបន្តពិនិត្យអ្នកបានដាក់ពាក្យទាំងអស់ ដោយទទួលបានអ្នកសង្កេតការណ៍គ្រប់លក្ខខណ្ឌចំនួន ៣៨នាក់។

ប្រការ ២._

ទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ នៅខេត្តស្ទឹងត្រែងចំនួន ៣៨ នាក់។

| ល.រ. | | គោត្តនាម-នាម | ភេទ |
|---|---|---|---|
| ១.មណ្ឌល បឋម. ស្ទឹងត្រែងក្រុង | | | |
| 1 | 1 | នី សុផានីត | ស្រី |
| 2 | 2 | កែវ សុនីតា | ស្រី |
| 3 | 3 | វ៉ង់ មូនីដា | ស្រី |
| 4 | 4 | ស៊ីនឿន ប៊ូឡឺ | ប្រុស |
| 5 | 5 | ស្រ៊ុន ម៉េងស៊ី | ប្រុស |
| 6 | 6 | ឡៅ វាសនា | ស្រី |
| 7 | 7 | ហឿង ប៊ុនធីម | ប្រុស |
| 8 | 8 | ជន ស្រីភ័ក្ត | ស្រី |
| ២. មណ្ឌល វិ. ព្រះរាជបូជនីយកិច្ច | | | |
| 9 | 1 | ធឿន ដានី | ស្រី |
| 10 | 2 | ម៉ន វុទ្ធី | ប្រុស |
| 11 | 3 | ហុង មុននាត | ប្រុស |
| 12 | 4 | ទុយ ស្រីនី | ស្រី |
| 13 | 5 | ហាម សុជាតា | ស្រី |
| 14 | 6 | ឈឿន សុជីឡា | ប្រុស |
| 15 | 7 | គីម លាង | ស្រី |
| 16 | 8 | ម៉ឺន លិន | ស្រី |
| 17 | 9 | ទក មករា | ស្រី |
| 18 | 10 | ប៊ុន វណ្ណា | ប្រុស |
| 19 | 11 | លឹម តារាវណ្ណ | ប្រុស |
| 20 | 12 | សេង រតនា | ស្រី |
| 21 | 13 | ហង់ សេងលី | ស្រី |
| 22 | 14 | ស៊ីណាល់ ហាហ្វីស្សា | ស្រី |
| 23 | 15 | ថៃ រស្មី | ស្រី |

| ល.រ. | | គោត្តនាម-នាម | ភេទ |
|---|---|---|---|
| ៣. មណ្ឌលមធ្យ. គរុ.ភូមិភាគឦសាន (សត) | | | |
| 24 | 1 | ម៉ឺន ស្រីរ័ត្ន | ស្រី |
| 25 | 2 | អេល ហ្វាទី | ស្រី |
| 26 | 3 | ឡិប ហ្វាទេល | ប្រុស |
| 27 | 4 | ទឹម ដាវ៉ាន់ | ស្រី |
| 28 | 5 | ផន ប៊ុនចាក់ | ប្រុស |
| 29 | 6 | ស៊ីន រស្មី | ស្រី |
| 30 | 7 | ខុន តាន់ | ប្រុស |
| 31 | 8 | ចាត ខែឡាត | ស្រី |
| 32 | 9 | ថា រចនា | ស្រី |
| 33 | 10 | អៀម សុខា | ស្រី |
| 34 | 11 | គឹម សុខាន់ | ប្រុស |
| 35 | 12 | អឿ សុវណ្ណារី | ស្រី |
| 36 | 13 | ប៊ិន រស្មី | ស្រី |
| 37 | 14 | រិទ្ធិ សុធារ៉ា | ប្រុស |
| 38 | 15 | យ៉េន រស្មី | ស្រី |

ប្រការ ៣._

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តស្ថិតក្រោមការចាត់តាំង ដឹកនាំ និងប្រគល់ភារកិច្ចរបស់ក្រុមការងារដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល។

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តត្រូវបំពេញភារកិច្ចឱ្យបានខ្ជាប់ខ្ជួនអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មានជាអាទិ៍ឧបសម្ព័ន្ធ២ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ កាតព្វកិច្ច និងវិន័យ សម្រាប់អ្នកសង្កេតការណ៍ស្ម័គ្រចិត្តនៃសេចក្តីណែនាំ ស្តីពីការងារសង្កេតការណ៍របស់អង្គភាពប្រឆាំងអំពើពុករលួយលើដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦។

ប្រការ ៤._

ក្រុមការងារដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល សាមីខ្លួនដូចមានក្នុងប្រការ ២ ខាងលើ និងផ្នែកពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ។

ថ្ងៃពុធ ១៤កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០២៦

ទេសរដ្ឋមន្ត្រី

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

កិត្តិនីតិកោសលបណ្ឌិត ឱម_យ៉ិនទៀង

**កន្លែងទទួល៖**

- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ



អគារលេខ ៥៤ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Website: www.acu.gov.kh, E-mail: complaint@acu.gov.kh, info@acu.gov.kh
Tel: 023 223 954, 023 221 653, Hotline: 1282